អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១១

# សេចក្តីប្រកាសព័ត៌មាន

## ព័ត៌មានស្តីអំពីការចូលរួមរបស់សាធារណជននិងអ្នកសារព័ត៌មាន នៅក្នុងសវនាការលើ អង្គសេចក្តីក្នុងសំណុំរឿង ០០២ នៅថ្ងៃទី ២១-២៤ ខែវិច្ឆិកា ឆ្នាំ២០១១ និងសវនាការពិនិត្យភ័ស្តុតាងដែលនឹងចាប់ផ្តើមនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១១

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានប្រកាសថា សវនាការលើអង្គសេចក្តីដើម្បីជំនុំជម្រះសំណុំរឿង០០២ ប្រឆាំងនឹង ខៀវ សំផន, នួន ជា, អៀង សារី, និង អៀង ធីរិទ្ធ នឹងចាប់ផ្តើមនៅវេលាម៉ោង **៩ ព្រឹក ថ្ងៃច័ន្ទ ទី២១ ខែវិច្ឆិកា ឆ្នាំ២០១១** ដូចមានក្នុងកម្មវិធីខាងក្រោម៖

<u>ថ្ងៃច័ន្ទ ទី២១ ខែវិច្ឆិកា ឆ្នាំ២០១១</u>

- ការអានបទចោទប្រកាន់ទាំងឡាយប្រឆាំងនឹងជនជាប់ចោទនីមួយៗ។
- ការថ្លែងសេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញា។

<u>ថ្ងៃអង្គារ ទី២២ ខែវិច្ឆិកា ឆ្នាំ២០១១</u>

- ការថ្លែងសេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញា (បន្ត)

<u>ថ្ងៃពុធ ទី២៣ ខែវិច្ឆិកា ឆ្នាំ២០១១</u>

- ការឆ្លើយតបរបស់ក្រុមមេធាវីការពារក្តី ទៅនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញា

<u>ថ្ងៃព្រហស្បតិ៍ ទី២៤ ខែវិច្ឆិកា ឆ្នាំ២០១១</u>

- ការឆ្លើយតបរបស់ក្រុមមេធាវីការពារក្តីទៅនឹងសេចក្តីសន្និដ្ឋានលើបទចោទប្រកាន់របស់សហព្រះរាជអាជ្ញា(បន្ត)

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

បន្ទាប់ពីការធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញា និងការឆ្លើយតបរបស់ក្រុមមេធាវីការពារក្ដីរួចមក សវនាការដើម្បីពិនិត្យលើភ័ស្ដុតាងនៅក្នុងសំណុំរឿង០០២ នឹងចាប់ផ្ដើមនៅវេលា ម៉ោង *៩ ព្រឹក ថ្ងៃច័ន្ទ ទី២៨ ខែវិច្ឆិកា ឆ្នាំ២០១១*។

**ព័ត៌មានសម្រាប់អ្នកចូលរួម**

សាលសវនាការមានកន្លែងអង្គុយចំនួន ៤៨២ កន្លែង ដែលនឹងត្រូវរៀបចំដូចតទៅ៖

1. **ដើមបណ្ដឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០២ និងតំណាងផ្លូវច្បាប់**

   កន្លែងអង្គុយចំនួន ២៣០ ត្រូវបានត្រៀមទុកសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវបានសម្របសម្រួលដោយអង្គភាពគាំពារជនរងគ្រោះ និងអង្គការអន្តរការី និងតំណាងផ្លូវច្បាប់របស់គាត់។ កន្លែងអង្គុយណាដែលនៅទំនេរត្រឹមម៉ោង ៨:៤៥ នាទី នឹងត្រូវផ្ដល់ជូនសាធារណជនទូទៅ។

2. **ភ្ញៀវអង្គទូត តំណាងរាជរដ្ឋាភិបាល និងអ្នកស្រាវជ្រាវ**

   កន្លែងអង្គុយចំនួន ៥០ ត្រូវបានត្រៀមទុកសម្រាប់ភ្ញៀវអង្គទូត តំណាងរាជរដ្ឋាភិបាល និងអ្នកស្រាវជ្រាវ។ សូមចុះឈ្មោះកក់កន្លែងទុកជាមុន តាមរយៈសារអេឡិចត្រូនិក pas@eccc.gov.kh។ ការចុះឈ្មោះកក់កន្លែងទុកជាមុននឹងផុតកំណត់នៅ**ថ្ងៃពុធ ទី១៦ ខែវិច្ឆិកា ឆ្នាំ២០១១ វេលាម៉ោង ៤ រសៀល**។ កន្លែងអង្គុយណាដែលនៅទំនេរត្រឹមម៉ោង ៨:៤៥ នាទី នឹងត្រូវផ្ដល់ជូនសាធារណជនទូទៅ។

3. **តំណាងរបស់អង្គការមិនមែនរដ្ឋាភិបាល**

   កន្លែងអង្គុយចំនួន ៥០ ត្រូវបានត្រៀមទុកសម្រាប់ឲ្យតំណាងរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលមានកម្មវិធីទាក់ទងនឹងការងាររបស់ អ.វ.ត.ក។ សូមចុះឈ្មោះកក់កន្លែងទុកជាមុនតាមរយៈសារអេឡិចត្រូនិក pas@eccc.gov.kh។ ការចុះឈ្មោះកក់កន្លែងទុកជាមុននឹងផុតកំណត់នៅ**ថ្ងៃពុធ ទី១៦ ខែវិច្ឆិកា ឆ្នាំ២០១១ វេលាម៉ោង ៤ រសៀល**។ ក្រោយពីផុតកំណត់រយៈពេលចុះឈ្មោះកក់កន្លែងទុកជាមុន និងអាស្រ័យលើចំនួនសរុបនៃអ្នកចុះឈ្មោះកក់កន្លែងទុកជាមុន អ.វ.ត.ក នឹងជូនដំណឹងអំពីចំនួនកន្លែងដែលបម្រុងទុកសម្រាប់អង្គការមិនមែនរដ្ឋាភិបាលនីមួយៗ។ ប្រសិនបើចំនួនអ្នកចុះឈ្មោះកក់កន្លែងទុកជាមុនលើសពីចំនួនកន្លែងអង្គុយសរុបដែលត្រៀមបម្រុងទុក អ.វ.ត.ក នឹងផ្ដល់កន្លែងអង្គុយដល់តំណាងអង្គការមិនមែនរដ្ឋាភិបាលនីមួយៗ ផ្អែកតាមអាទិភាពដូចខាងក្រោម៖

   ក. បុគ្គលិកមកពីអង្គការអន្តរការី

   ខ. បុគ្គលិកពាក់ព័ន្ធនឹងកម្មវិធីត្រួតពិនិត្យតុលាការជាទៀងទាត់

៣. អង្គការមិនមែនរដ្ឋាភិបាលដែលមានវត្តមានទៀងទាត់នៅក្នុងសវនាការកាលពីលើកមុនៗ។

៤. ផ្សេងៗទៀត

កន្លែងអង្គុយណាដែលនៅទំនេរត្រឹមម៉ោង ៨:៤៥ នាទី នឹងផ្តល់ជូនសាធារណជនទូទៅ។

## 4. តំណាងសារព័ត៌មាន

កន្លែងអង្គុយចំនួន ២០ នៅក្នុងសាលសវនាការ នឹងបម្រុងទុកសម្រាប់តំណាងសារព័ត៌មាន។ អាទិភាពនឹងផ្តល់ឲ្យដល់អ្នកសារព័ត៌មានខាងផ្នែកបោះពុម្ពជាមុន។ សូមចុះឈ្មោះកក់កន្លែងទុកជាមុន តាមរយៈសារអេឡិចត្រូនិក pas@eccc.gov.kh។ ការចុះឈ្មោះកក់កន្លែងទុកជាមុននឹងផុតកំណត់នៅ**ថ្ងៃពុធ ទី១៦ ខែវិច្ឆិកា ឆ្នាំ២០១១ វេលាម៉ោង ៤ រសៀល**។ សមាជិកអ្នកសារព័ត៌មានដែលនៅសេសសល់ នឹងត្រូវបានផ្តល់កន្លែងអង្គុយនៅក្នុងបន្ទប់សារព័ត៌មាន C105 នៅជាន់ផ្ទាល់ដីនៃអគារ តុលាការ។

## 5. សាធារណជនទូទៅ

កន្លែងអង្គុយចំនួន៥០នឹងត្រៀមសម្រាប់ផ្តល់ជូនសាធារណជនទូទៅតាមគោលការណ៍មកមុនបានមុន។

ទ្វារច្រកចូលសម្រាប់ភ្ញៀវនឹងបើកនៅម៉ោង ៧ព្រឹក នៅថ្ងៃសវនាការនីមួយៗ។ អ.វ.ត.ក ណែនាំឲ្យអ្នកចូលរួមគួរតែមកដល់ច្រកត្រួតពិនិត្យសន្តិសុខឲ្យបានមុន ដើម្បីទុកពេលវេលាគ្រប់គ្រាន់សម្រាប់ការត្រួតពិនិត្យសន្តិសុខនិងការចែកសំបុត្រចូល។ អ.វ.ត.ក នឹងបិទច្រកចូលទៅកាន់សាលសវនាការនៅម៉ោង ៨:៤៥ នាទីព្រឹក ឬនៅពេលដែលសាលសវនាការមានមនុស្សអង្គុយពេញ។

សូមរំឭកថា ដើម្បីចូលក្នុងសាលសវនាការ អ្នកចូលរួមទាំងអស់ត្រូវតែបង្ហាញប័ណ្ណសម្គាល់ខ្លួន (ដែលមានបិទរូបថត) ដល់សន្តិសុខនៅច្រកមាត់ទ្វារខាងក្រៅ។ អ្នកដែលមានអាយុក្រោម១៦ឆ្នាំ នឹងមិនត្រូវបានអនុញ្ញាតឲ្យចូលរួមឡើយ ហើយអ្នកដែលមានអាយុចន្លោះពី១៦ដល់១៨ឆ្នាំ អាចចូលបានលុះត្រាតែមានមនុស្សចាស់មកជាមួយ។ សាធារណជនត្រូវតែរក្សាភាពថ្លៃថ្នូរ និងអាកប្បកិរិយាសមរម្យគ្រប់ពេលវេលា និងត្រូវមានសម្លៀកបំពាក់សមរម្យ។ មិនអនុញ្ញាតឲ្យយកទូរស័ព្ទដៃ កាបូបធំៗ អាហារ ឬភេសជ្ជៈ ចូលក្នុងសាលសវនាការឡើយ។

អ.វ.ត.ក មានទីតាំងនៅសង្កាត់ចោមចៅ ចម្ងាយ ១៦គីឡូម៉ែត្រ ពីរាជធានីភ្នំពេញតាមផ្លូវជាតិលេខ៤ ឆ្ពោះទៅកាន់ខេត្តព្រះសីហនុ។ សូមអញ្ជើញសាធារណជននិងអ្នកសារព័ត៌មានចូលតាមច្រកសម្រាប់ភ្ញៀវដែលស្ថិតនៅផ្នែកខាងកើតនៃ អ.វ.ត.ក។ អ.វ.ត.ក មានទីធ្លាសម្រាប់ភ្ញៀវចតយានយន្ត។

**ការចុះឈ្មោះសុំប័ណ្ណព័ត៌មានសម្រាប់អ្នកសារព័ត៌មាន**

អ្នកសារព័ត៌មានដែលមានបំណងចូលរួមតាមដានដំណើរការសវនាការរបស់ អ.វ.ត.ក នៅថ្ងៃទី ២១-២៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ត្រូវតែមានប័ណ្ណសម្រាប់អ្នកសារព័ត៌មាន និងត្រូវចុះឈ្មោះជាមុន។ សូមអនុវត្តតាមលក្ខខណ្ឌខាងក្រោមដើម្បីសុំប័ណ្ណព័ត៌មាន៖

ក) អ្នកសារព័ត៌មានដែលកំពុងកាន់ប័ណ្ណព័ត៌មានមានសុពលភាពជាផ្លូវការរបស់ អ.វ.ត.ក ត្រូវចុះឈ្មោះនៅផ្នែកកិច្ចការសាធារណៈ តាមរយៈការផ្ញើសារអេឡិចត្រូនិកទៅកាន់ PAS@ECCC.GOV.KH។

ខ) អ្នកសារព័ត៌មានដែលមានប័ណ្ណព័ត៌មានជាផ្លូវការរបស់ អ.វ.ត.ក ប៉ុន្តែផុតកំណត់ ត្រូវបំពេញទម្រង់បែបបទសុំប័ណ្ណព័ត៌មានសាជាថ្មី ដោយមានចុះហត្ថលេខាផង និងផ្ញើមកជាមួយនឹងសំណើសុំចុះឈ្មោះតាមរយៈសារអេឡិចត្រូនិកPAS@ECCC.GOV.KH។សូមកុំភ្លេចបញ្ជាក់លេខប័ណ្ណចាស់ដែលផុតកំណត់។

គ) អ្នកសារព័ត៌មានដែលមិនទាន់មានប័ណ្ណព័ត៌មានដែលចេញដោយ អ.វ.ត.ក ត្រូវបំពេញទម្រង់បែបបទសុំប័ណ្ណសារព័ត៌មានដោយមានចុះហត្ថលេខា ភ្ជាប់រូបថតទម្រង់ jpg មួយសន្លឹក និងច្បាប់ចម្លងលិខិតឆ្លងដែនមួយច្បាប់ ផ្ញើមកជាមួយសំណើសុំចុះឈ្មោះតាមរយៈសារអេឡិចត្រូនិក PAS@ECCC.GOV.KH។

ទម្រង់បែបបទសម្រាប់សុំប័ណ្ណព័ត៌មាន អាចទាញយកបានពីគេហទំព័ររបស់ អ.វ.ត.ក: http://www.eccc.gov.kh/sites/default/files/ECCC_Accreditation_Media_Application_Form.doc.

អ.វ.ត.ក ត្រៀមបម្រុងកន្លែងអង្គុយចំនួន ២០កន្លែង នៅក្នុងសាលសវនាការសម្រាប់តំណាងសារព័ត៌មាន។ អាទិភាពនឹងត្រូវបានផ្តល់ជូនអ្នកសារព័ត៌មានខាងផ្នែកបោះពុម្ព។ អ្នកសារព័ត៌មានដទៃទៀតនឹងត្រូវរៀបចំជូនកន្លែងអង្គុយក្នុងបន្ទប់សារព័ត៌មាននៅជាន់ផ្ទាល់ដី។ តំណាងសារព័ត៌មានដែលមានបំណងទទួលបានកន្លែងអង្គុយក្នុងសាលសវនាការ ត្រូវធ្វើសំណើសុំកន្លែងអង្គុយព្រមគ្នាជាមួយនឹងសំណើសុំចុះឈ្មោះសម្រាប់ការចូលរួមស្តាប់សវនាការ។

អ្នកសារព័ត៌មានត្រូវតែមកដល់កន្លែងអង្គុយរបស់ខ្លួនឲ្យបាន ១៥នាទី មុនពេលបើកសវនាការ។ ពុំអនុញ្ញាតឲ្យយកម៉ាស៊ីនថតរូប កុំព្យូទ័រយួរដៃ ទូរស័ព្ទដៃ ឬឧបករណ៍ថតសំឡេង ចូលក្នុងសាលសវនាការឡើយ។

***ថ្ងៃផុតកំណត់ឈប់ទទួលការចុះឈ្មោះរបស់អ្នកសារព័ត៌មាន៖ ថ្ងៃពុធ ទី១៦ ខែវិច្ឆិកា ឆ្នាំ២០១១***

**ការផ្តល់ជូនអ្នកសារព័ត៌មាន**

ផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក នឹងផ្តល់មធ្យោបាយនានានៅជាន់ផ្ទាល់ដីនៃអគារសវនាការ ដើម្បីជួយ

សម្រួលដល់អ្នកសារព័ត៌មានក្នុងអំឡុងពេលសវនាការ។

នៅក្នុងបន្ទប់ការងារព័ត៌មាន (C108) នៅជាន់ផ្ទាល់ដីនៃអគារសវនាការ មានទីកន្លែងស្ងប់ស្ងាត់សម្រាប់ធ្វើការ និងមានកុំព្យូទ័រមួយចំនួនដែលភ្ជាប់ប្រព័ន្ធអ៊ីនធឺណិតរួចជាស្រេច សម្រាប់អ្នកសារព័ត៌មានប្រើប្រាស់តាមគោលការណ៍មកមុនបានមុន។ សូមបញ្ជាក់ថា សេវាអ៊ីនធឺណិតគ្មានខ្សែនៅ អ.វ.ត.ក នៅមានកម្រិតនៅឡើយ ដូច្នេះអ្នកសារព័ត៌មានគួរតែយកម៉ូឌឹម 3G (3G modems) ផ្ទាល់ខ្លួនមកជាមួយ ប្រសិនបើអ្នកសារព័ត៌មានត្រូវការបញ្ជូន ឬទាញយកឯកសារទំហំធំៗ។

នឹងមានផ្តល់ការផ្សាយបន្តផ្ទាល់ជាវីដេអូ និងសំឡេងអំពីដំណើរការសវនាការ នៅក្នុងបន្ទប់សម្រាប់អ្នកសារព័ត៌មាន (C105) ដែលស្ថិតនៅជាន់ផ្ទាល់ដីនៃសាលសវនាការ។ ការផ្សាយបន្តផ្ទាល់ជាភាសាខ្មែរនៅក្នុងបន្ទប់ C109 និងភាសាអង់គ្លេសនៅក្នុងបន្ទប់ C105។

## ការថតរូបភាព

ផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក នឹងផ្តល់រូបភាពដែលមានគុណភាពខ្ពស់នៅពេលចាប់ផ្តើមសវនាការ។

## ការថតសំឡេង

ការផ្សាយសំឡេងអំពីដំណើរការសវនាការ នឹងត្រូវបានផ្តល់ជូនអ្នកសារព័ត៌មានតាមប្រព័ន្ធ PHONO/XLR។ អ្នកសារព័ត៌មានអាចថតការផ្សាយសំឡេងនេះបាននៅក្នុងបន្ទប់តាមដានព័ត៌មាន (C105) ដោយប្រើឧបករណ៍ភ្ជាប់មួយក្នុងចំណោមឧបករណ៍ភ្ជាប់ចំនួន ៤៨ (មានឧបករណ៍ភ្ជាប់ចំនួន១៦ សម្រាប់ភាសានីមួយៗ មានខ្មែរ អង់គ្លេស និងបារាំង)។ ការតភ្ជាប់ពីម៉ាស៊ីនថតសំឡេងមួយទៅម៉ាស៊ីនថតសំឡេងមួយទៀត អាចធ្វើទៅបានប្រសិនបើអ្នកសារព័ត៌មានមានខ្សែសម្រាប់តភ្ជាប់។ ពុំអនុញ្ញាតឲ្យថតសំឡេងនៅក្នុងសាលសវនាការឡើយ។

## ការថតវីដេអូ

ការផ្សាយវីដេអូអំពីដំណើរការសវនាការ នឹងត្រូវបានផ្តល់ជូនតាមប្រព័ន្ធ BNC (PAL signal)។ អ្នកសារព័ត៌មានអាចចម្លងវីដេអូ នៅក្នុងបន្ទប់តាមដានព័ត៌មាន (C105) ដោយប្រើប្រាស់ឧបករណ៍ភ្ជាប់មួយក្នុងចំណោមឧបករណ៍ភ្ជាប់ចំនួន ៣០ ដែលមាននៅទីនោះ។ ការតភ្ជាប់ពីម៉ាស៊ីនថតវីដេអូមួយទៅម៉ាស៊ីនវីដេអូមួយទៀត អាចធ្វើទៅបានប្រសិនបើអ្នកសារព័ត៌មានមានខ្សែសម្រាប់តភ្ជាប់។ ពុំអនុញ្ញាតឲ្យថតវីដេអូនៅក្នុងសាលសវនាការឡើយ។

## ការដំឡើងឧបករណ៍សារព័ត៌មាន និងការកក់ទុកកន្លែងជាមុននៅបន្ទប់សារព័ត៌មាន C105

អ្នកសារព័ត៌មានដែលមានបំណងចង់ដំឡើងឧបករណ៍ជាមុន និងកក់កន្លែងជាមុននៅក្នុងបន្ទប់សារព័ត៌មាន អាចមកទស្សនា អ.វ.ត.ក ***នៅថ្ងៃសុក្រ ទី១៨ ខែវិច្ឆិកា ចន្លោះពីម៉ោង ៩ព្រឹក ដល់ម៉ោង ២រសៀល ឬនៅថ្ងៃអាទិត្យ ទី២០ ខែវិច្ឆិកា ឆ្នាំ២០១១ ចន្លោះពីម៉ោង ១០ព្រឹក ដល់ម៉ោង ៣រសៀល។***

**មធ្យោបាយដឹកជញ្ជូនដោយឥតគិតថ្លៃសម្រាប់អ្នកសារព័ត៌មាន**

អ.វ.ត.ក នឹងផ្តល់ការដឹកជញ្ជូនដោយរថយន្តក្រុងដោយឥតគិតថ្លៃដល់អ្នកសារព័ត៌មានដែលពុំមានយានជំនិះផ្ទាល់ខ្លួន សម្រាប់ធ្វើដំណើរមកកាន់ អ.វ.ត.ក និងត្រឡប់ទៅវិញ។ រថយន្តក្រុងនឹងចាប់ផ្តើមចេញដំណើរពីមជ្ឈមណ្ឌលព័ត៌មានរបស់ អ.វ.ត.ក ដែលមានទីតាំងនៅផ្ទះលេខ ៦អា ផ្លូវលេខ ២១ សង្កាត់ទន្លេបាសាក់ខ័ណ្ឌចំការមន នៅវេលា ម៉ោង ៧:០០ព្រឹក ហើយនឹងមកដល់មុខស្ថានីយ៍រថភ្លើងនៅវេលាម៉ោងប្រមាណ ៧:១៥នាទី នៃថ្ងៃសវនាការ។ អ្នកសារព័ត៌មានដែលចង់ជិះរថយន្តក្រុងត្រូវតែចុះឈ្មោះនៅផ្នែកកិច្ចការសាធារណៈជាមុនតាមរយៈ pas@eccc.gov.kh។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោក **ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃ៖ +៨៥៥(០)១២ ៤៨៨ ០២៣
ទូរស័ព្ទ៖ +៨៥៥(០)២៣ ២១៩ ៨៤១ លេខបន្ត ៦១៦៩
សារអេឡិចត្រូនិក៖olsenl@un.org

លោក **នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃ៖ +៨៥៥(០)១២ ៤៨៣ ២៨៣
សារអេឡិចត្រូនិក៖
neth.pheaktra@eccc.gov.kh